# OMI0007

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសជាមួយឈ្មោះ ចាន់ ភីម ភេទប្រុស អាយុ៥៥ឆ្នាំ ក្រៅប្រវត្តិរូប
## មុខងារសព្វថ្ងៃៈ ជាងសិប្បកម្ម
## រស់នៅភូមិស្រះឈូក ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ
## ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨
## សម្ភាសដោយៈ ឡុង ដានី

ដានី ៖ អត់ទោសពូបងខ្ញុំចង់ស្គាល់ឈ្មោះអ អ៊ំឈ្មោះអីដែរ?

ភីម ៖ បាទ! ខ្ញុំឈ្មោះចាន់ ភីម ។

ដានី ៖ ឈ្មោះចាន់ ភីម?

ភីម ៖ បាទ!

ដានី ៖ អាយុប៉ុន្មានហើយ?

ភីម ៖ អាយុ៥៥ឆ្នាំ ។

ដានី ៖ អ៊ំមានស្រុកកំណើតកើតជានៅណាដែរ?

ភីម ៖ ខ្ញុំកំណើតកើតជានៅខត្តក្ត ។

ដានី ៖ នៅភូមិអីគេ នៅខត្តក្ត?

ភីម ៖ ខត្តក្តនៅក្រាំងភ្ជារ ។

ដានី ៖ ក្រាំងភ្ជារ ឃុំអីគេ?

ភីម ៖ ឃុំវាលពង្ស ។

ដានី ៖ ឃុំវាលពង្ស ស្រុកខត្តក្ត?

ភីម ៖ បាទ! ស្រុកខត្តក្ត ។

ដានី ៖ ឪពុកម្តាយឈ្មោះអីទៅ?

ភីម ៖ ឪពុកម្តាយស្លាប់អស់ ។

ដានី ៖ គាត់ឈ្មោះអី?

ភីម ៖ ឪពុកឈ្មោះភួង ។

ដានី ៖ ម្តាយ?

ភីម ៖ ម្តាយក៏ស្លាប់ ។

ដានី ៖ គាត់ឈ្មោះអីដែរ?

ភីម ៖ ញាង ។

ដានី ៖ មានបងប្អូនប៉ុន្មាននាក់ដែរ?

ភីម ៖ បងប្អូនតែម្នាក់ឯង ក្រៅពីនឹងស្លាប់អស់ ។

ដានី ៖ អញ្ចឹងខ្ញុំចង់ឲ្យអ៊ំរៀបរាប់ប្រវត្តិពីជីវិតអ៊ំត្រួសៗ តាំងពីក្មេងរហូតដល់ឆ្លងកាត់ក្នុងសម័យ៣ឆ្នាំ រហូតមកដល់បច្ចុប្បន្ន អ៊ំអាចរៀបរាប់?

ភីម ៖ ជម្រាបលោកកាលពីក្មេង កាលពីដើមឡើង មុនឆ្នាំ១៩៧០ ខ្ញុំនៅជាមួយឪពុកម្តាយ មានឪពុកមានម្តាយដែរ ហើយរបររកស៊ីខ្ញុំឡើងតែត្នោតទេ ធ្វើស្រែធ្វើចំការនឹង ។

ដានី ៖ ម៉េចទៀតទៅ?

ភីម ៖ មានអីទៀត ។

ដានី ៖ បាទ! បន្ទាប់ពីឡើងត្នោតហើយ យ៉ាងម៉េចទៀតទៅ?

ភីម ៖ ដល់តែពេលយើង៧១ ៧២ ជិតសម័យសង្គ្រាមកើតឡើង ក៏ខ្ញុំជំនាន់នឹងគេថាធ្វើបដិវត្តក៏ធ្វើនឹងគេទៅ ។

ដានី ៖ ស្ម័គ្រចិត្ត?

ភីម ៖ ស្ម័គ្រចិត្តអីគេបង្ខំ ដោយសារសមាគមន៍គេក្នុងភូមិគេមិនឲ្យនៅ ខ្ញុំអត់មានការពិតខ្លួនខ្ញុំអត់មានអ្នកណាបម្រើឪពុកម្តាយទេ តែដល់ដូចថាតែម្នាក់ឯង ឪពុកម្តាយគាត់ចាស់ ។ ដល់យើងនៅមិនបាន គេកសាងគេអីច្រើនយើងក៏មកចូលធ្វើនឹងគេទៅ តាំងពីជំនាន់នឹងមក ៧៣ ។

ដានី ៖ ចូលឆ្នាំប៉ុន្មាន?

ភីម ៖ ៧៣ ។

ដានី ៖ ចុះពី៧១ ៧២ធ្វើអី?

ភីម ៖ ធ្វើស្រែ ទៅបួស កាល៧១ ៧២បួសៗ ៧៣នឹងសឹកៗគេនៅផ្ទះមិនបានក៏គេឲ្យធ្វើបដិវត្តក៏មកនឹងគេ ។

ដានី ៖ បដិវត្តធ្វើនៅណាខ្លះទៅ?

ភីម ៖ ធ្វើនៅស្រុកនឹង ។

ដានី ៖ ធ្វើរហូតដល់ពេលណា?

ភីម ៖ ពេលដល់រហូតដល់៧៥ ។

ដានី ៖ ៧៥ ពូនៅណាទៅ?

ភឹម ៖ ៧៥ យើងគេរំដោះភ្នំពេញមក ខ្ញុំក៏គេឲ្យចូលមកភ្នំពេញមក នៅធ្វើសហករណ៍នៅភ្នំពេញនឹងម៉ង ។

ដានី ៖ ភ្នំពេញធ្វើសហករណ៍នៅណា?

ភឹម ៖ នៅភ្នំពេញនឹងម៉ង ។

ដានី ៖ នៅភ្នំពេញ នៅម្តុំណា?

ភឹម ៖ កាលនឹងនៅអាដូវពេទ្យលោកសង្ឃៗ គេឲ្យនៅម្តុំនឹង ។

ដានី ៖ អង្គភាពអីគេអានឹង?

ភឹម ៖ ខ្ញុំអង្គភាព កាលនឹងអង្គភាពពួកទ័ពដែរ តែគេឲ្យខ្ញុំពិការទ់ងគេឲ្យទៅនៅនឹង ដល់ខ្ញុំពិការទៅគេឲ្យទៅនៅភ្នំពេញនឹងឯង ពិការនឹងត្រូវនេះផ្លាយមកនេះបាក់ដៃ ។

ដានី ៖ ពិការតាំងពីឆ្នាំណា?

ភឹម ៖ អានឹងតាំងពី៧៤ ។

ដានី ៖ ៧៤?

ភឹម ៖ បាទ! ដល់បាក់ដៃទៅគេឲ្យទៅនៅនឹងទៅ ។

ដានី ៖ ពិការនឹងកាលពេលវ៉ៃគ្នាជាមួយ?

ភឹម ៖ គ្រាប់ថ្លោងៗ ៦០ ។

ដានី ៖ គ្រាប់ថ្លោងខាង លន់ នល់?

ភឹម ៖ បាទ! ខាងហ្នឹង ។

ដានី ៖ ដល់ឆ្នាំ៧៥ធ្វើការនៅសហករណ៍ ធ្វើស្រែ ធ្វើអី?

ភឹម ៖ បាទ! ហ្នឹងឯង ។

ដានី ៖ នៅខាងពេទ្យលោកសង្ឃ?

ភឹម ៖ បាទ! នៅខាងពេទ្យលោកសង្ឃ ។

ដានី ៖ អានឹងក្រុមពិការ?

ភឹម ៖ បាទ! ពិការ ។

ដានី ៖ ពេលធ្វើការនៅសហករណ៍ នៅក្រុមពិការនឹង លោកពូមានធ្លាប់ជួបព្រឹត្តិការណ៍អីខ្លះទេ?

ភឹម ៖ អត់ទេ ខ្ញុំអត់មានបានអីនៅពិការ គេឲ្យដាំបន្លែដាំអី យើងគ្រាន់ដាំហូបដាំអី យើងគ្រាន់ដាំហូបខ្លួនឯង ។

ដានី ៖ មានធ្លាប់ជួបដូចជាទំនាក់ទំនងអីជាមួយប្រជាជន?

ភីម ៖ អត់ទេ កាលនឹងអត់មានប្រជាជនទេ គេឲ្យពួកពិការខ្ញុំនឹងទៅដាំបាយដាំអី ឃើញតែពួកខ្ញុំនឹងម៉ង អត់មានអី ។

ដានី ៖ ពិការនឹងនៅកន្លែងសហករណ៍នឹងដល់ពេលណាទៅ?

ភីម ៖ ដល់ពេលយើងវៀតណាមចូលស្រុក ។

ដានី ៖ នៅនឹងរហូតដល់ឆ្នាំ៧៩ម៉ង?

ភីម ៖ បាទ! ៧៩ ។

ដានី ៖ នៅកន្លែងពិការនឹង ពូធ្លាប់ដូចថាមកលេងស្រុក ឬក៏មក?

ភីម ៖ អត់ទេ ជំនាន់នឹងគេមិនឲ្យយើងមក សូម្បីតែផ្ទះនឹងនៅជិតក៏គេមិនឲ្យយើងមកដែរ ដែលម៉ែឪទៅណាបែកបាក់គ្នារហូតមកដល់សព្វថ្ងៃមិនបានមកជួបទៀត ឡើងបាត់អត់ ។

ដានី ៖ ដូចថាក្រៅពីនៅកន្លែងពិការនឹង ធ្វើស្រែ ធ្វើអី ក្រៅពីនឹងគេមានឲ្យធ្វើអីទៀត?

ភីម ៖ អត់ទេ ដល់ពេលយើងដល់សម័យយើង៨០ ៨១ ៨២ ៨៣ហើយណា ៨៣មកក៏ខ្ញុំវាដាច់ជើងក៏អារឈើធ្វើគ្រែ ខ្ញុំធ្វើសិប្បកម្ម ធ្វើជាង រោងជាងខ្ញុំប៉ុនណាណៃ មានអាជីពមួយពិតប្រាកដនៅនឹងម៉ង ។

ដានី ៖ នៅណា?

ភីម ៖ នោះរោងជាងខ្ញុំប៉ុនណាណៃ ខ្ញុំធ្វើបណ្ដោះបណ្ដាលសុទ្ធតែពួកពិការរបស់ខ្ញុំ ខ្ញុំមានអាជីពនឹងមួយច្បាស់លាស់ម៉ង ដល់អញ្ចឹងទៅកូនចៅខ្ញុំបំបែកទៅបានទៅកូនទៅចៅ បានចេះទាំងអស់គ្នា ។

ដានី ៖ ដូចថាក្នុងចន្លោះពី៧៥មក៧៩នឹង ពូដូចថាធ្លាប់មានរាប់អានជាមយប្រជាជន ឬក៏មានទំនាក់ទំនងល្អជាមួយ?

ភីម ៖ ៧៥ហ្នឹង?

ដានី ៖ ចន្លោះពី៧៥-៧៩?

ភីម ៖ អត់ៗបាន អានឹងវាដល់ពេល៧៩នឹងខ្ញុំក៏រត់មកនឹងគេមកនឹងឯង ៧៥-៧៩វានៅតែក្នុងពិការ ដល់៧៩ខ្ញុំរត់ឡើងភ្នំដងរែងនឹងគេដែរ ។

ដានី ៖ ជំនាន់៧៩រត់ឡើងភ្នំដងរែកដែរ?

ភីម ៖ បាទៗ ។

ដានី ៖ ហេតុអីបានឆ្នាំ៧៩ ពូរត់ឡើងភ្នំដងរែក?

ភីម ៖ អឺ! ចុះវៀតណាមចូលស្រុកនោះ បាទ!៧៩វៀតណាមចូល ។

ដានី ៖ ចុះហេតុអីបានអត់រត់ទៅផ្ទះ?

ភីម ៖ រត់ទៅផ្ទះឯណា បើផ្ទះអត់ មកទាំងអស់គ្នាមក គេដាក់រទេះភ្លើងមក ពួកពិការគេដាក់រទេះភ្លើងមក ។

ដានី ៖ គេដាក់រទេះភ្លើងមកខាងណា?

ភីម ៖ មកបាត់ដំបងមកតាមផ្លូវបាត់ដំបងនឹងមក ហើយខ្ញុំធាក់មកសៀមរាបចេះមក បាទ!រសាត់ៗគ្រែងៗមានឡានទៅណាជិះទៅនឹងគេទៅ វាដើរទៅអត់រួច ។

ដានី ៖ ដល់ពេលរត់ឡើងលើភ្នំដងរែកហើយមកខាងសៀមរាបអីយ៉ាងម៉េចទៀតទៅ?

ភីម ៖ ដល់មកសៀមរាប យើងមកដល់ មកដល់សៀមរាបនឹងយើងមកដល់ភ្នំដងរែកនឹងហើយឡើងដល់ភ្នំហើយ ។ ដលឡើងដល់ភ្នំកាលនឹងចលនាគេនឹង គេប្រាប់ឲ្យយើងធ្វើការដឹកជញ្ជូនដឹកអីណា តែខ្ញុំវាមានអាជីពមួយ ដូចថាយើងឆ្លៀតពីនឹងទៅ យើងអារឈើធ្វើគ្រែ ធ្វើអីលក់ៗឲ្យប្រជាជនថៃ ។ យើងកាលនឹងខ្ញុំដើរទៅជាន់មីន ឆ្នាំ៨៤នឹងខ្ញុំជាន់មីនដាច់ជើង ។

ដានី ៖ ដល់ពេលពីឆ្នាំ៨៩អីមក ពូឡើងមកនេះមកធ្វើបង្កើតជាសិប្បកម្មអារឈើអារអីនឹង?

ភីម ៖ បាទ! ពេលយើងធ្វើអត់មានបានអារបានអីទេ ធ្វើអាឈើតូចតាចៗធ្វើលក់ដើម្បីចិញ្ចឹមក្រពះដើររកលុយអីខ្លះ ។ ដល់ពេលខ្ញុំពិការដាច់ជើងមែនទែននេះ ឆ្នាំ៨៤នេះ បានខ្ញុំធ្វើស៊ុបតែម៉ងធ្វើបង្កើតជាក្រុមធ្វើម៉ង ។

ដានី ៖ ឆ្នាំ៨៤?

ភីម ៖ បាទ! ៨៤ ៨៥ ចុង៨៤ ដើម៨៥ខ្ញុំដាច់ជើង ដល់ខ្ញុំជាពីជើងទៅ ខ្ញុំអត់មានមុខរបរអ្វីខ្ញុំធ្វើតែសិប្បកម្មរហូត ហើយបើមិនជឿលោកទៅមើលតែរោង ។ ពីមុនខ្ញុំធ្វើមិនមានគ្នា មិនតូចទេ ៣០នាក់នោះធ្វើៗ ជាមួយរុំឈ្មោះរុំមិញនឹង ធ្វើតែសិប្បកម្ម ។

ដានី ៖ អញ្ចឹងពេលដែលក្រោយ៧៩ ពេលពូមកភ្នំដងរែកមកអីនឹង ពូធ្លាប់មានទំនាក់ទំនង ឬក៏ធ្លាប់រាប់អានជាមួយប្រជាជនមកពីខាងក្នុង ឬកជួបជួយពួកគាត់អីយ៉ាងម៉េចដែរ?

ភីម ៖ បាទ! អានឹងខ្ញុំបានធ្លាប់ជួយដល់ឆ្នាំ១៩៩៦ អានឹងខ្ញុំបាន ព្រោះខ្ញុំនៅកាលនឹងខ្ញុំមានអគ្គភាពខ្ញុំនឹង គេធ្វើតុធ្វើសាឡុង ធ្វើទូធ្វើគ្រែធ្វើទូ ធ្វើគ្រែធ្វើសាឡុង ដល់ពេលហ្នឹងខ្ញុំឃើញប្រជាជនកាលនឹងប្រជាជនដែលភៀសខ្លួនមក ប្រជាជនមកពីគេហៅពីនឹងទៅនៅតំបន់ៗខាងរដ្ឋាភិបាល មានខាងខ្ញុំទេ ។ ដល់អញ្ចឹងទៅប្រជាជនមកអញ្ចឹងទៅ គេឲ្យខ្ញុំទៅដឹកអង្ករដឹកក្រណាត់ដឹកអីទៅជួយគាត់ មានតែប៉ុននឹងឯងពីឆ្នាំ៩៦នឹង ។

ដានី ៖ ឆ្នាំ៩៦នឹង?

ភីម ៖ បាទ!៩៦ ខែ៤ វាខ្ញុំចាំវាមិនសូវច្បាស់ តែកំណត់ថាប៉ុននឹងឯងវាថែមថ្ងៃ តែខ្ញុំដឹងថាទៅដល់ វាវស្សាធ្លាក់ភ្លៀងខ្ញុំមកវិញ ខ្ញុំដើរឡានអត់កើត ដើរគោយន្តខ្ញុំនេះ គោយន្តវាទៅអត់

រួច វាផុតហើយ ។

ដានី ៖ ចុះពីមុនឆ្នាំ៩៦ ពូមានធ្លាប់ជួប ឬធ្លាប់ជួយអី រាប់អានអី?

ភីម ៖ អត់បានទេៗ បានខ្ញុំវិលវល់អារឿងអាជីពសិប្បកម្មនឹងនៅតែនឹង សូម្បីតែស្រែខ្លួនឯងដែលជិតៗនឹងអត់សូវបានធ្វើផង ។ បាទ! ហើយខ្ញុំនៅនេះអត់មានដីនឹងគេដែរ កាលជំនាន់នឹងយើងអត់មានបានទៅចាប់ដីចាប់ធ្លីអីណា ខ្ញុំជម្រាបបងនឹងតែទៅគាត់គិតតែពីរឿង ព្រលឹមឡើងម៉ោង៧-៨ធ្វើ ម៉ោង១០-១១បាយ ហើយឈប់ធ្វើ ហើយដល់អញ្ចឹងពង្រីកឲ្យកូនឲ្យចៅរាល់ថ្ងៃនឹង កូនចៅដែលនៅផ្ទះជាប់ៗនេះវាបានចេះទាំងអស់គ្នាទៅ វាមានអាជីពមួយបានដល់រាល់ថ្ងៃនឹង វាបានអាជីពនឹងហើយសម្រាប់ខ្ញុំពិការចិញ្ចឹមជីវិត ។

ដានី ៖ កាលពីឆ្នាំ៩៦ដែលពូថាធ្លាប់ជួយប្រជាជននឹង ជួយយ៉ាងម៉េចអាចពូជួយរៀបរាប់ឲ្យលំអិតតិច?

ភីម ៖ បាទ! ពេលនឹងខ្ញុំចេះទេ ព្រោះទៅជួយគាត់នឹងឃើញគាត់ដូចថាមកពីក្នុងមកៗ កាលនឹងវាជាងកាលនឹងប្រហែលជិត១០០នាក់ដែរនឹង ៧០-៨០នាក់ដែរនឹងប្រជាជន ហើយខ្ញុំឃើញគាត់មកអញ្ចឹងទៅ ខ្ញុំមានអង្ករមានក្រណាតមានអីសុំគេយកទៅៗជួយ មានតែប៉ុននឹងឯងបានម្ដងនឹងឯងជួយគាត់ ។

ដានី ៖ ប្រជាជន១០០នាក់មកពីខាងក្នុងមកនឹង?

ភីម ៖ ប្រហែល៧០-៨០នាក់មានស្រីមានប្រុស ប្រុសតិចទេតែស្រីៗ ។

ដានី ៖ តាមគាត់ជិត៨០នាក់នឹងមកៗពីខាងណា?

ភីម ៖ មកៗពីខាងគោកស្រុក គោកឫស្សីនឹង ។

ដានី ៖ មកពីគោកស្រុក គោកឫស្សី?

ភីម ៖ បាទ! ស្រុកភ្នំរិន ។

ដានី ៖ មូលហេតុអីបានគាត់មក?

ភីម ៖ គាត់រត់មក គាត់ភៀសខ្លួនដូចថាវាវ៉ៃគ្នានៅក្នុងភូមិគាត់ៗរត់មក មានសង្គ្រាមកើតនៅក្នុងភូមិគាត់ៗរត់ចេញមក ។

ដានី ៖ មានសង្គ្រាមអញ្ចឹងគាត់រត់ចេញមក?

ភីម ៖ បាទ! ដល់គាត់រត់ចេញមកៗអត់បាយអត់ទឹក ។

ដានី ៖ មកៗគាត់នៅកន្លែងណា?

ភីម ៖ នៅទំនប់ថ្មីៗយើង ។

ដានី ៖ ក្នុងស្រុកអន្លង់វែងយើងដែរ?

ភីម ៖ បាទ! ក្នុងស្រុកអន្លង់វែងយើងដែរ ។

ដានី ៖ មកទំនប់ថ្មី?

ភីម ៖ បាទ! ទំនប់ថ្មីយើងទំបន់ ។

ដានី ៖ ដល់ពេលមកអញ្ចឹង ពូដូចថាដោយចិត្តខ្លួនយើងជួយគាត់ដោយចិត្តខ្លួនឯងឬក៏គេអង្គភាពគេ?

ភីម ៖ គេអង្គភាពគេឲ្យដឹកអីទៅជួយ ។

ដានី ៖ អង្គភាពគេឲ្យដឹកទៅជួយ?

ភីម ៖ បាទ! អង្គភាពគេឲ្យប្រើខ្ញុំឲ្យទៅ ព្រោះខ្ញុំវាអាជីបការងារនេះទេ ដល់គេអត់មនុស្សប្រើ គេប្រើខ្ញុំទៅ ប្រើខ្ញុំឲ្យយកអង្ករ យកក្រណាត់យកអីទៅឲ្យប្រជាជននឹង ។ ហើយប្រជាជន គាត់អត់ឃ្លានគាត់អត់មានឆ្នាំងដាំអី ខ្ញុំក៏យកទៅឲ្យបានមួងនឹងឯង បានពេលនឹងប្រជាជនគាត់អរគាត់បានស្គាល់រាក់ទាក់គ្នាទៅ រាប់អានគ្នាជាបងជាប្អូននៅពេលថ្ងៃ តែឥឡូវមិនដឹងទៅណាទៅណែអត់ទេ វាបែកបាក់គ្នា ។ ខ្ញុំមិនដែលបានទៅដល់ផ្ទះគាត់ គាត់ក៏មិនដែលមកផ្ទះខ្ញុំប្រជាជន ។

ដានី ៖ ពេលដែលពូដឹកអង្ករ ដឹកក្រណាត់ឲ្យនឹង ដូចថាយើងត្រូវចែកឲ្យពួកគាត់យ៉ាងម៉េចដែរ?

ភីម ៖ ចែកឲ្យម៉ាគ្រួសារឆ្នាំងមួយ ឆ្នាំងដាំបាយស្ល ឆ្នាំងដាំបាយ អង្ករម្នាក់ម៉ាកំប៉ុង បើម្នាក់ម៉ាខែអញ្ចឹងទៅឲ្យគាត់ម្នាក់៦០កំប៉ុងអញ្ចឹងទៅ ឲ្យ៦០កំប៉ុង ។

ដានី ៖ ម្នាក់៦០កំប៉ុង?

ភីម ៖ ម្នាក់៦០កំប៉ុងក្នុងម៉ាខែម្នាក់ ហើយខ្ញុំទៅពេលនឹង ខ្ញុំទៅបានម៉ាខែទេ ខែ៤ ខែ៥នឹងខ្ញុំត្រឡប់មកវិញ ព្រោះខ្ញុំការងារនៅនេះ ។

ដានី ៖ ចែកឲ្យគាត់?

ភីម ៖ បាទ! បានម៉ាខែ ។

ដានី ៖ គាត់នឹងមកស្នាក់នៅប៉ុន្មាន?

ភីម ៖ នៅយូរ នៅទើលសព្វថ្ងៃៗក៏គាត់នៅដែរ គាត់អត់ទៅណា មកណា គាត់នៅភូមិគាត់ កើតទឹកកើតដីកើតផ្ទះគាត់នៅនឹងទៅ ។

ដានី ៖ កាលជំនាន់នោះ ពូមានស្គាល់ឈ្មោះក្នុងចំណោម២០នាក់ដែលពូធ្លាប់ទៅជួយនឹងនៅចាំឈ្មោះដែរអត់?

ភីម ៖ អឺ!ភ្លេចអស់ហើយ ប្រជាជនច្រើន ខ្ញុំមិនសូវបាន ។

ដានី ៖ មានរាប់អានអីពួកគាត់អត់?

ភីម ៖ រាប់អាន គាត់មកលេងផ្ទះតើ តែខ្ញុំវាភ្លេចឈ្មោះវាយូរហើយភ្លេចឈ្មោះគាត់ តែស្រីៗទេ

អត់មានសុទ្ធតែនារីៗប៉ុនៗក្មួយៗនឹងមកបែកម៉ែ បែកឪនឹងខ្ញុំក៏យកអង្ករ យកអីទៅក្រណាត់សារ៉ុងអីទៅឲ្យ ។ ហើយខ្ញុំក៏នឹកឃើញហើយ ខ្ញុំនេះវាបច្ចេកទេសជំនាញខាងជាងគុ ជាងទអត់អ្នកណាផ្ញើខ្ញុំមកវិញ ។

ដានី : ភាគច្រើនស្រី ក្នុងចំណោម?

ភីម : បាទ!ស្រីប្រហែលជាប់២០នាក់ ៣០នាក់ដែរនឹង ហើយចាស់ៗម៉ង សុទ្ធតែចាស់ៗបែកកូនមកតែម៉ែ ខ្ញុំ ។

ដានី : អញ្ចឹងសព្វថ្ងៃពួកគាត់ទាំងជិត៨០នាក់នឹងនៅរស់នៅ?

ភីម : នៅនឹងផ្ទះនឹង នៅភូមិនឹងឯង តែគាត់ទៅនេះ ទៅស្រុកកំណើតខ្លះហើយ ។

ដានី : ទៅស្រុកកំណើត?

ភីម : បាទ! ហើយខ្ញុំក៏តាំងពីនឹងមក អត់ដែលទៅអើតកន្លែងនឹងទេ អត់ដែលបានទៅមើលវា អត់មានអីទៅវាពិបាកដើរនៅតែនឹងទៅ សូម្បីទៅណា តែពីនេះទៅជួល់បើថាម៉ាគីឡូពីរគីឡូក៏ខ្ញុំអត់ដែលបានដើរ បើដើរមានតែទៅសៀមរាបទៅផ្ទះនោះម៉ង ទៅស្រុកទៅបងប្អូននៅភ្នំពេញទៅតែនឹងម៉ង ។ គិតតែខំរកដូចថាផ្ញើខំរកចិញ្ចឹមកូន ចិញ្ចឹមចៅប្រពន្ធអី ខ្ញុំវាកូនច្រើនដែរនោះកូនវាតូចច្រើន ដល់យើងវាខំរកចិញ្ចឹមកូន ។

ដានី : ពូមូលហេតុដែលពួកគាត់៨០នាក់គាត់មកពីស្រុកមក ដោយសារសង្គ្រាម?

ភីម : សង្គ្រាមកើតមាននៅភូមិគាត់ ។

ដានី : សង្គ្រាមខាងៗណា?

ភីម : កាលនឹងមានរដ្ឋាភបាលជាមួយខ្មែរក្រហម ។

ដានី : ដូចថាកន្លែងនឹង ភូមិគាត់នឹងគេច្រើនកន្លែងសមរភូមិមក?

ភីម : បាទ! ច្រើនសមរភូមិមក ។

ដានី : អញ្ចឹងគាត់រត់មកខាង?

ភីម : ហើយខ្ញុំបើថាភូមិនឹងពុតែឈ្មោះដែរទេ ខ្ញុំអត់ដែលបានស្គាល់ថាភូមិនឹងម៉េចទៀតទេ អត់ដែលបានទៅដល់ភូមិនឹងទេ ទៅអត់រួច ។ ដែលទៅៗយកអីៗដែលយកទៅឲ្យគាត់នឹង ដឹកគោយន្តខ្លួនឯងទៅម៉ង មានគោយន្តខ្លួនឯងទៅដឹក ។

ដានី : ចុះពូមានធ្លាប់មានជួយក្រៅពីប្រជាជនជិត៨០នាកនឹង ប្រជាជនផ្សេងទៀតដូចថាធ្លាប់ជួបគ្នា ឬក៏កន្លែងណាមួយពូធ្លាប់ផ្តល់ចំណីអាហារ ឬក៏ជួយពួកគាត់ឲ្យរួចផុតពីការសម្លាប់ ឬក៏ជួយជូនពួកគាត់ទៅជំរុំ ដូចថាជំរុំតាមទល់ដែនទៅអីផ្សេងៗនឹង ពូមានធ្លាប់ទេ?

ភីម ៖ អត់ទេ បើគេអត់មានដែលបានជួយគេទេ ខ្ញុំផ្ទាល់ខ្លួនឯងបើបានគេថាជួយបើអត់បាន ដល់យើងអត់មានបានជួយអ្នកណាទៀត ដល់បានតែប៉ុននឹង ខ្ញុំមនោសញ្ចេតនារបស់គាត់អររីករាយពេលដែលខ្ញុំឲ្យគាត់នឹង កាលពីមុនគាត់ព្រួយបារម្ភដែរ វាអត់បាយអត់ទឹកកូនចៅរញ៉េរញ៉ៃ ដល់ពេលខ្ញុំយកដាក់គោយន្តទៅឲ្យអញ្ចឹងទៅ គាត់មានអារម្មណ៍មួយគឺសប្បាយរីករាយល្អរាប់អានគាត់មករហូត មកដល់សព្វថ្ងៃខ្ញុំមិនដែលបានទៅលេងផ្ទះគាត់ ។ បើខ្ញុំទៅ ជួនកាលជួបគាត់នៅស្រែណាយអី គ្រាន់អីអើៗភ្លេចឈ្មោះគាត់ តែវាទៅរយៈពេលខ្ញីបានម៉ាខែហើយភ្លៀងដល់ភ្លៀងមកខ្ញុំទៅមកអត់រួច ។

ដានី ៖ ចុះពូមានស្គាល់អ្នកណាទៀតដែលគាត់ដូចថាធ្លាប់ដូចខ្ញុំជម្រាបមិញគាត់ធ្លាប់បានជួយប្រជាជនរួចពីការសម្លាប់ ដូចជាជួយផ្តល់ចំណីអាហារ ឬក៏ជួយជូនពួកគាត់ដូចរត់មិញអញ្ចឹង ពូអាចស្គាល់ពីណាដែលគាត់ធ្លាប់ជួយអញ្ចឹងៗ ?

ភីម ៖ នៅកន្លែងនេះដូចមិនមានទេ មិនមានទេជួយពីដើម ជួយមានតែដូចជំរុំ ដូចខាវឌីដាង ដូចអូរគ្រាវដូចអីពីដើមអានឹង មានអង្គការកាកបាទក្រហមជួយម៉ង អានឹងប្រជាជនរាប់ពាន់ រាប់ម៉ឺន ។

ដានី ៖ អត់ទេ ដូចថាពេលដែលគាត់ធ្វើដំណើរឆ្លងកាត់ពីកន្លែងមួយទៅកន្លែងមួយ ដូចថាកន្លែងនឹងវង្វេងផ្លូវ ឬស្អីគាត់អាណិតជួយប្រាប់ផ្លូវ ឬជួយជូនទៅនោះ?

ភីម ៖ ដូចអស់ ដូចអត់ដែលឃើញ អត់មាន វាអត់ ។

ដានី ៖ ហើយមួយទៀតដូចជំនាន់៣ឆ្នាំ ជំនាន់៧៥-៧៩ពេកធ្វើការនឹង គាត់ធ្លាប់ជួយផ្តល់ចំណី ឬក៏គាត់ជួយឲ្យគាត់ប្រជាជននឹងរួចផុតពីការស្លាប់អីអញ្ចឹង ឬក៏ធ្លាប់មានរាប់អានជាមួយជនជាមិត្តជាភ័ក្ត្រ ជាបងជាប្អូន ឬក៏យ៉ាងម៉េច?

ភីម ៖ ជំនាន់៣ឆ្នាំកាលនឹងខ្ញុំនៅវ័យក្មេង ការធ្វើដូចថាវាលំបាកខ្លួនឯង វារកកន្លែងវាមិនដឹងដែរ កាលជំនាន់នឹង បើខ្ញុំកាលនឹងវានៅពិការ ទៅណាគេមិនរួចដែរ ផ្ទះខ្លួនឯងមិនបានទៅមើលទៀត មិនដឹងជាបងប្អូនវាយ៉ាងម៉េច ដល់ពេលឥឡូវបានយើងជួបគ្នា មិនដឹងថាបងប្អូនគេស្លាប់អស់ទៅហើយ ។

ដានី ៖ បាទ! ខ្ញុំចង់ជម្រាបប្រាប់ពូម៉ាសារទៀត ថាពួកខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ៗនឹងមានតួនាទីប្រមែមប្រមូលឯកសារពីអំឡុងឆ្នាំ១៩៧៥-៧៩ ។ ហើយយើងប្រមែមប្រមូលឯកសារនេះ មានការអនុញ្ញាតិពីខាងរាជរដ្ឋាភិបាល ដើម្បីចងក្រងទុកជាឯកសារប្រវត្តិសាស្ត្រពីរបបកម្ពុជាប្រជាធិបតេយ្យនឹង ដើម្បីដូចថាយើងស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះ ។ ហើយខ្ញុំមកដល់ផ្ទះពូនេះ ដោយសារខ្ញុំចង់ដឹងរឿងរ៉ាវដូចខ្ញុំបានជម្រាបពូមិញអញ្ចឹង ថាគោលបំណង

របស់ខ្ញុំៗចង់ជួបអតីតកម្មាភិបាល យុទ្ធជនដែលគាត់ធ្លាប់ជួយដល់ជនរងគ្រោះ ដែលជាប្រជាជនមិនមែនជាអ្នកមូលដ្ឋានអីអញ្ចឹង ។ អញ្ចឹងពូមានអីចង់បន្ថែមនូវអ្វីដែលពួកខ្ញុំអត់បានសួរនាំអី ក្រែងលរពូមានអីបន្ថែមអាចជា ។

ភីម : អត់មានអីបន្ថែម បានមកសួរខ្ញុំក៏អរគុណដែរនឹង តែវាមិនដឹងមានអីបន្ថែមសម្រាប់បំពេញរឿងខាងផ្នែកអីទៀត អ្វីដែលខ្ញុំដឹង ខ្ញុំជម្រាបបានតើ មិនដឹងវាយើងមិនច្បាស់ដូចថាអ្វីដែលយើងដឹងដូចខ្ញុំជម្រាបបានមិញអញ្ចឹង ខ្ញុំជម្រាបម៉ង ព្រោះវាដូចថាភាគច្រើនរាប់សិបឆ្នាំ២០ ៣០ឆ្នាំ ដូចខ្ញុំមានអាជីពដូចខ្ញុំជម្រាបអញ្ចឹងវាគិតតែរឿងបង្កើតអាជីពមួយសម្រាប់ខ្លួនឯងដល់ពេលពិការទៅនេះ មានដឹងថានឹកឃើញរកអី ម៉្លោះហើយបើធ្វើស្អីក៏ធ្វើមិនកើត គិតតែខំអានឹងព្យាយាមអានឹងដើម្បីចិញ្ចឹម ។ អញ្ចឹងបានខ្ញុំនឹកគុណក្មួយ កុំបានខ្លួនឯងមានគំនិតចាប់វិជ្ជាសិប្បកម្មទេ បើថាអត់ជីវិតខ្ញុំមិនដឹងធ្វើអីបានៗ វេទនាមហាវេទនា បងប្អូនពិការដែលនៅនេះ ខ្ញុំមើលឃើញគ្នាដែលគ្នាអត់មានអាជីព ធ្វើការយ៉ាប់ៗ ហើយខ្ញុំជាមួយប្តីប្រពន្ធព្រឹកឡើងឈូសៗថ្ងៃឡើងឈូស ដៃឡើងក្រិនអស់ហើយឈូសឈើនឹង ហើយប្រឹងៗអញ្ចឹង ម៉ង រកស៊ីបានតិចតួច រកស៊ីបានទាល់តែឡូវខ្ញុំចាស់ហើយកូនចៅវាចេះគ្រប់គ្នាទៅខ្ញុំឈប់ធ្វើ ខ្ញុំទុកការងារនឹងឲ្យកូនទៅវិញ ដល់អញ្ចឹងវល់ទៅវិញ ។

ដានី : សព្វថ្ងៃពូរស់នៅភូមិអីគេដែរ?

ភីម : ភូមិស្រះឈូក ។

ដានី : ឃុំ?

ភីម : ឃុំត្រពាំងប្រិយ៍ ។

ដានី : ស្រុក?

ភីម : អន្លង់វែង ។

ដានី : សព្វថ្ងៃពូប្រកបមុខរបរ?

ភីម : ធ្វើសិប្បកម្ម ដល់ឥឡូវខ្ញុំឈប់ធ្វើអានឹងទៅ ខ្ញុំធ្វើចំការ ខ្ញុំមានចំការដាំដំឡូងមី ដាំអីទៅ ខ្ញុំខំប្រឹងតិច វាយើងមិនបានទៅធ្វើខ្លួនឯងទេ គ្រាន់បាននេះអីទៅឲ្យគេជួលគេទៅដាំអីទៅណា ។

ដានី : អញ្ចឹងអរគុណច្រើន ។

«ចប់»